សំណួរទី 1
ក្នុងចំណោមឃ្លាខាងក្រោម តើមួយណាដែលនិយាយអំពី "ជើងទម្ររុញ" ដែលប្រើប្រាស់ក្នុងការងារជីកផ្លូវរូងរុញទៅមុខ?

1. ជាបំពង់ដែលប្រើក្នុងវិធីសាស្ត្ររុញទៅមុខ។
2. ជាជើងទម្រសម្រាប់នាំបំពង់រុញទៅមុខទៅកម្ពស់និងទិសដៅដែលបានកំណត់។
3. ជារបស់ដែលបញ្ជូនកម្លាំងប្រតិកម្មរបស់ម៉ាស៊ីនរុញ (jack) ចម្បង ឲ្យស្មើគ្នាទៅដីផ្នែកខាងក្រោយ។
4. ជាជើងទម្រសម្រាប់រុញចេញម៉ាស៊ីនជីកទៅមុខយកត្រឡប់មកវិញ។

ចម្លើយ៖ 2

# វិញ្ញាសាគំរូ ការប្រឡងវាយតម្លៃពលករជំនាញកម្រិត 2 ផ្នែកសំណង់ (អនុវត្តន៍សំណង់ស៊ីវិល)

សំណួរទី 2
ក្នុងការងារសំណង់ស៊ីវិលសមុទ្រ សម្ភារដែលដាក់នៅជុំវិញការដ្ឋានសំណង់ដើម្បីផ្តល់ដំណឹងដល់នាវាដែលមិនពាក់ព័ន្ធការងារសំណង់អំពីការដ្ឋានសំណង់ តើហៅថាអ្វី?

1. ពោងសំគាល់
2. យុថ្កា
3. ម៉ាស៊ីនរលកសូរ(Sonar)
4. ខ្សែវាស់ជម្រៅ(sounding line)



ចម្លើយ៖ 1

សំណួរទី 3
ក្នុងចំណោមឃ្លាខាងក្រោម តើមួយណាដែលនិយាយអំពីគោលបំណងដែលប្រើលួសចំណង?

1. វាស់ប្រវែងសរសៃដែក
2. ចងសរសៃដែកនិងសរសៃដែក
3. ថ្លឹងទម្ងន់សរសៃដែក
4. ពិនិត្យធាតុផ្សំគីមីរបស់សរសៃដែក

ចម្លើយ៖ 2

សំណួរទី 4
ផ្លូវថ្នល់ដែលត្រូវបានក្រាល រួមផ្សំដោយស្រទាប់ចំនួន 4 ហើយក្នុងចំណោមខាងក្រោមតើមួយណាដែលមិនត្រូវបានរួមបញ្ចូលក្នុងស្រទាប់ទាំង 4 នោះ?

1. ស្រទាប់ផ្ទៃខាងលើកម្រាលថ្នល់
2. គ្រឹះថ្នល់
3. ស្រទាប់ដីសម្រាំង
4. ស្រទាប់មានទឹក

ចម្លើយ ៖ 4

សំណួរទី 5
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង(           )ក្នុងប្រយោគខាងក្រោម។

ការងារ() គឺធ្វើឡើងដើម្បីធ្វើឲ្យកម្រិតទឹកនៃទឹកក្រោមដីដែលមានទីតាំងនៅជិតស្រទាប់ដី មានកម្រិតទាប ហើយបង្កើតដីគ្រឹះរឹងមាំ។

1. ខួងអណ្ដូង
2. ការពារជម្រាបទឹក
3. បំពង់ស្រូបទឹក
4. សំណង់ស៊ីវិលសមុទ្រ

ចម្លើយ៖ 3

សំណួរទី 6
ចូរជ្រើសរើសអ្វីដែលមិនត្រឹមត្រូវ នៅក្នុងការងារការពារជម្រាល។

1. ការបាញ់បាយអគឺត្រូវធ្វើពីខាងក្រោមទៅ
2. ក្នុងករណីដែលផ្ទៃដែលបាញ់គឺជាដីខ្សាច់ ត្រូវប្រយ័ត្នកុំឲ្យដីខ្សាច់ហុយបាចសាចដោយសារកម្លាំងបាញ់
3. ក្នុងករណីដែលផ្ទៃដែលបាញ់គឺជាផ្ទាំងថ្ម ត្រូវកម្ចាត់ចេញថ្មអណ្ដែត ដីភក់ សំរាមជាដើមជាមុនសិន
4. ការស្រោចទឹកលើស្មៅដែលបានក្រាល នៅថ្ងៃមេឃស្រឡះត្រូវធ្វើនៅពេលព្រឹកឬពេលល្ងាចដោយជៀសវាងពេលថ្ងៃត្រង់។

ចម្លើយ៖ 1

សំណួរទី 7
ចូរជ្រើសរើសអ្វីដែលត្រឹមត្រូវក្នុងនាមជាវិធានការការពារជំងឺស្ត្រូកកម្តៅ។

1. ជៀសវាងទទួលទានទឹកនិងជាតិអំបិលមុននិងក្រោយធ្វើការងារ
2. ពាក់សម្លៀកបំពាក់ការងារដែលមិនហប់
3. កុំប្រើកន្លែងសម្រាកដែលមានម៉ាស៊ីនត្រជាក់
4. ពេលកំពុងធ្វើការ ទោះបីមិនស្រួលខ្លួន ក៏ត្រូវទ្រាំដែរ

ចម្លើយ៖ 2